# ខេត្តបន្ទាយមានជ័យ

## ថ្ងៃពុធ ទី១៩ ខែសីហា ឆ្នាំ១៩៩៨

នៅព្រឹកព្រលឹមថ្ងៃពុធទី១៩ ខែសីហា ឆ្នាំ១៩៩៨ វេលាម៉ោង ៦:៤៥នាទី ក្រុមស្រាវជ្រាវយើងបានចេញដំណើរពីខេត្តបាត់ដំបងឆ្ពោះទៅខេត្តបន្ទាយមានជ័យក្នុងចំងាយផ្លូវ ......... គីឡូម៉ែត្រ ។ ក្នុងការធ្វើដំណើររបស់ក្រុមស្រាវជ្រាវយើងនេះ គឺមានលក្ខណៈពិបាកណាស់ ព្រោះផ្លូវដែលយើងធ្វើដំណើរនោះមានសភាពចាស់ទ្រុឌទ្រោម, ជាច់ក្រហេងក្រហូងស្ទើរតែបើកបរពុំរួច ម្យ៉ាងទៀតជារដូវវស្សាផង ដែលជាហេតុធ្វើអោយកាន់តែមានការលំបាកទ្វេរឡើង ដោយផ្លូវរអិល ។ ដូច្នេះការធ្វើដំណើររបស់យើងត្រូវប្រើពេលអស់ពីរម៉ោងកន្លះ ។

នៅវេលាម៉ោង ៩:១០នាទី ក្រុមយើងបានទៅដល់សាលាខេត្តបន្ទាយមានជ័យ បន្ទាប់មកយើងបានជួបលោកអភិបាលរងទី៣ ខេត្ត ឈ្មោះ **អ៊ុច ម៉ុន** ដើម្បីទំនាក់ទំនងសំណុំបែបបទរដ្ឋបាល ។ បន្ទាប់មកលោកអភិបាលរង បានបញ្ជាអោយបុគ្គលិករដ្ឋបាលម្នាក់ធ្វើលិខិតជាផ្លូវការមួយ ដោយបានឯកភាព និងយល់ព្រមអោយក្រុមស្រាវជ្រាវយើងចុះទៅតាមបណ្តាស្រុកនានាក្នុងទូទាំងខេត្ត ។

ខេត្តបន្ទាយមានជ័យមានព្រំប្រទល់ :

- ខាងជើង និងខាងលិច ជាប់នឹងប្រទេសថៃ ប្រវែង ២៦៤គីឡូម៉ែត្រ
- ខាងកើត និងខាងត្បូង ជាប់នឹងខេត្តបាត់ដំបង និងខេត្តសៀមរាប
- ចំនួនផ្ទៃដីរួម : ៧.៨៦៩ គីឡូម៉ែត្រការ៉េ
- ផ្ទៃដីបង្កបង្កើនផល : ២.៤៥៥,៥ គីឡូម៉ែត្រការ៉េ
- ផ្ទៃដីព្រៃ : ៤.៥៨៤,៥ គីឡូម៉ែត្រការ៉េ
- ផ្ទៃដីស្ទឹងបឹងបួរ : ៩០៥ គីឡូម៉ែត្រការ៉េ
- ផ្ទៃដីលំនៅដ្ឋាន : ១៣០ គីឡូម៉ែត្រការ៉េ
- ចំនួនប្រជាជនរួម : ៥៧៧.៧៣៣ នាក់

  ក្នុងនោះមានស្រី : ២៨៩.៤២៣ នាក់

- មាន៩ស្រុក គឺស្រុកសេរីសោភ័ណ, មង្គលបុរី, អូរជ្រៅ, ព្រះនេត្រព្រះ, ភ្នំស្រុក, ស្វាយចេក, ថ្ម ពួក, បន្ទាយអំពិល និងស្រុកម៉ាឡៃ ។
- មាន ៦៥ឃុំ ដែលទទួលស្គាល់ដោយអនុក្រិត្យ និងឃុំចំនួន៣ ដែលសុំបង្កើតថ្មី ។

- មាន ៥៦៩ភូមិ ដែលទទួលស្គាល់ដោយអនុក្រឹត្យ និងភូមិចំនួន ៨៤ ដែលសុំបង្កើតថ្មី

ក្រោយពីបានជួបសំណេះសំណាល និងបំពេញបែបបទរដ្ឋបាលជាមួយឯកឧត្តមអភិបាលរងទី៣ខេត្តរួច យើងក៏បានធ្វើដំណើរទៅកាន់ស្រុកមួយចំនួនដែលយើងចង់ទៅ ។

## I. ស្រុកសេរីសោភ័ណ

នាពេលនេះ ក្រុមអ្នកស្រាវជ្រាវយើងមិនបានជួបលោកអភិបាលស្រុកទេ ព្រោះពេលនោះគាត់ជាប់រវល់ត្រូវចេញទៅខាងក្រៅ ដើម្បីទំនាក់ទំនងការងារផ្សេងៗ ដោយពេលវេលាចេះតែរំកិលទៅមុខ ក្រុមស្រាវជ្រាវយើងមិនអាចនៅរង់ចាំលោកអភិបាលស្រុកបានទេ, ដូច្នេះយើងបានធ្វើដំណើរត្រឡប់មកកាន់មន្ទីរពតិមានស្រុកវិញ ។

នៅវេលាម៉ោង ១០:១៨នាទី នាថ្ងៃដដែល ក្រុមស្រាវជ្រាវយើងបានមកជួបជាមួយលោក **ធាល់ សំអឿន** ជាប្រធានមន្ទីរពតិមានស្រុកសេរីសោភ័ណ ។ ក្នុងពេលជួបជាមួយលោក **ធាល់ សំអឿន** នោះ យើងក៏បានជួបជាមួយសហការីរបស់លោកចំនួនពីរនាក់ទៀត គឺលោក **អ៊ុក សឿន** ប្រធានផ្នែកទូរទស្សន៍-វិទ្យុ និងលោក **ស៊ី សុមិត្រ** ជាប្រធានរដ្ឋបាល ។

លោកប្រធានមន្ទីរបានប្រាប់យើងថា ក្នុងស្រុកសេរីសោភ័ណនេះ មានទីតាំងសម្លាប់មួយធំជាងគេ គឺនៅតំបន់ចំការខ្នុរ ដែលស្ថិតនៅខាងជើងវត្តគីរីជុំ ចំការខ្នុរ និងភ្នំស្វាយ ។ តំបន់នេះស្ថិតនៅក្នុងភូមិអូរអំបិល ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ លោកបានបន្តថា នៅទីនោះសព្វថ្ងៃនៅមានស្លាកស្នាមបន្សល់ទុក ដូចជារណ្តៅធំៗ ដែលលុបមិនជិតជាដើម ។ កាលពីទើបតែរំដោះថ្មីៗ រណ្តៅដែលកប់សាកសពនេះ ត្រូវបានប្រជាជនក្នុងភូមិ ឃុំ ខាងលើ ជីកកកាយ និងឆែកឆេរខ្លួនរបស់សាកសពដើម្បីរកមាស និងគ្រឿងអលង្ការផ្សេងៗ ដែលធ្វើឱ្យសាកសពទាំងនោះហាក់លេចចេញនៅលើដីក្នុងរណ្តៅ ព្រោះក្រោយពីឆែកឆេររួច ប្រជាជនទាំងនោះមិនបានកប់វិញទេ ។ លោក **អ៊ុក សឿន** ប្រធានវិទ្យុ-ទូរទស្សន៍ បានបញ្ជាក់ថា ក្នុងរណ្តៅធំមួយៗ មានសាកសពរាប់រយនាក់ ព្រោះជារណ្តៅធំ ហើយជ្រៅជាង ។ លោកបានបន្តថា ចំនួនសាកសពទាំងអស់ក្នុងតំបន់ចំការខ្នុរនេះមានប្រហែលពី ៤០០០ ទៅ ៥០០០ នាក់។ ចំណែកលោក **ស៊ី សុមិត្រ** ក៏បានបញ្ជាក់ផងដែរថា អដ្ឋិធាតុនៃសាកសពទាំងនោះភាគច្រើនត្រូវបាន ប្រជាជនក្នុងភូមិអូរអំបិលជីកជញ្ជូនយកមកតំកល់ទុកនៅវត្តសុភមង្គល ដែលស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ខាងលើ ។

ក្រោយពីបានបរិយាយប្រាប់អ្នកស្រាវជ្រាវយើងរួច លោកទាំង៣ បានសុខចិត្តធ្វើជាសាក្សី និងធានាថាអ្វីដែលលោកទាំងបី បាននិយាយនោះ សុទ្ធសឹងតែជាការពិត និងបានឃើញផ្ទាល់ភ្នែក ។

នៅម៉ោង ១១:០២នាទី បន្ទាប់ពីក្រុមស្រាវជ្រាវយើង បានដឹងពត៌មានពីមន្ត្រីស្រុកសេរីសោភ័ណ រួច យើងក៏ប្រញាប់ប្រញាល់ធ្វើដំណើរមកកាន់វត្តសុភមង្គលភ្នាម ដើម្បីចុះទៅពិនិត្យផ្ទាល់នូវស្តូបមួយ ដែលតំកល់អដ្ឋិធាតុប្រជាជនដែលបានស្លាប់ក្នុងរបបផ្តាច់ការប្រល័យពូជសាសន៍ ។ មិនតែប៉ុណ្ណោះ យើង បានទៅជួបលោកគ្រូសូត្រវត្តសុភមង្គលព្រះនាម **សៀន ញាណ** ព្រះជន្ម ៦៩ព្រះវស្សាទៀត ព្រះ អង្គបានគូសបញ្ជាក់ប្រាប់យើងថា នៅចំការខ្នុរនេះមានការសម្លាប់ទាំងខ្សែៗ ហើយប្រភេទជនរងគ្រោះ មានលាយចំរុះគ្នា ប៉ុន្តែភាគច្រើនគឺជាអនិកជនវៀតណាម ដែលបានមករស់នៅតាំងពីយូរយារណាស់មក ហើយ ហើយអនិកជនចិន, ឡាវ និងចាម ក៏មានស្លាប់នៅទីនោះដែរ ។ ព្រះអង្គបានបន្តថា តាមការប៉ាន់ ស្មានចំនួនមនុស្សដែលស្លាប់នៅចំការខ្នុរ នេះមានចំនួនពី ៤០០០ ទៅ ៤៥០០នាក់ ហើយចំពោះអដ្ឋិធាតុ វិញ ត្រូវបានព្រះអង្គព្រះនាម **សៀន ញាណ** ផ្ទាល់តែម្តង ដែលជាអ្នកដឹកនាំប្រជាជនក្នុងភូមិអោយ ទៅជីកយកមកដាក់តំកល់ក្នុងស្តូបនាវត្តសុភមង្គលនេះ ។ ព្រះអង្គបានបន្ថែមថា ការសម្លាប់មនុស្សនៅ ចំការខ្នុរនេះ គឺចាប់ផ្តើមនៅឆ្នាំ១៩៧៦ ហើយបន្តរហូតមកដល់ចុងឆ្នាំ១៩៧៨ ។ ព្រះអង្គបានប្រាប់ថា កាលពីជំនាន់ **ប៉ុល ពត** ព្រះអង្គរស់នៅឃុំសំរោង ស្រុកសេរីសោភ័ណ ហើយក្រោយថ្ងៃរំដោះព្រះអង្គ បានវិលមករស់នៅឃុំអូរអំបិលវិញ ។

ដូច្នេះព្រះអង្គគ្រូសូត្រនៃវត្តសុភមង្គលឈ្មោះ **សៀន ញាណ** បានស្ម័គ្រចិត្តធ្វើសាក្សីក្នុង រឿងឧក្រិដ្ឋកម្មខាងលើរបស់ខ្មែរក្រហមមកលើប្រជាជនក្នុងភូមិ ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ។

ដោយស្ថានភាពនៅស្រុកសេរីសោភ័ណ មានលក្ខណៈល្អប្រសើរ ជាពិសេសនៅតំបន់ចំការខ្នុរ ក្នុង ឃុំអូរអំបិលមានស្ថេរភាពល្អ អាចអោយក្រុមស្រាវជ្រាវយើងចុះទៅពិនិត្យផ្ទាល់បាន ទើបនៅវេលាម៉ោង ១២:៤៥នាទី យើងបានបន្តដំណើរចេញពីវត្តសុភមង្គលឆ្ពោះទៅកាន់តំបន់ចំការខ្នុរ ។ នាពេលនោះ យើង បានចូលទៅកាន់វត្តគីរីជុំចំការខ្នុរ ដែលមានចំងាយប្រហែល ៣គីឡូម៉ែត្រពីផ្លូវជាតិ និងនៅខាងកើតភ្នំ ស្វាយ ។ បន្ទាប់មកយើងបានជួបនឹងគណៈកម្មការវត្តម្នាក់ឈ្មោះ **សោម ឡាច** ដែលបានឃើញផ្ទាល់ ភ្នែកនូវសកម្មភាពរបស់ប្រជាជនក្នុងការជីកកកាយរកមាស ហើយព្រមទាំងបានបញ្ជាក់ថា រណ្តៅសាក សពទាំងនេះ គឺជីកដោយត្រាក់ទ័រ ដែលរណ្តៅចំនួនមួយ ដែលធំជាងគេ គឺមានទទឹង ៥ម៉ែត្រ និងបណ្តោយ ២០០ម៉ែត្រ និងមានជំរៅ ១ម៉ែត្រ ហើយក្រៅពីនេះមានរណ្តៅបន្ទាប់បន្សំចំនួន ៤ទៀត ដែលមានទំហំ ប្រហែល ៤ម៉ែត្រការ៉េ ។ លោកតា **សោម ឡាច** បានប្រាប់យើងថា លោកមានអាយុ ៦៣ឆ្នាំ កាល ពីសម័យ **ប៉ុល ពត** គាត់រស់នៅស្រុកមោង ខេត្តបាត់ដំបង ហើយក្រោយថ្ងៃរំដោះ គាត់ក៏បានមករស់ នៅក្នុងភូមិ ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ពេលនោះលោកតា បានប៉ាន់ស្មានថា

សាកសពដែលបានស្លាប់ក្នុងចំការខ្នុរនេះមានប្រហែលរាប់ពាន់អ្នក ព្រោះនៅក្នុងរណ្តៅដ៏ធំមួយនេះ អាចមានមនុស្សស្លាប់លើសពី ៥០០នាក់ ។

ទីតាំងតំបន់ចំការខ្នុរនេះស្ថិតនៅចំងាយប្រហែល ២០០ម៉ែត្រ ពីវត្តគីរីជុំចំការខ្នុរភាគខាងជើង និងមានចំងាយប្រហែល ២០០ម៉ែត្រ ដែលពីភ្នំស្វាយ ភាគខាងជើងដូចគ្នា ។ ហើយជាពិសេសទៅទៀត ទីតាំងវត្តគីរីជុំចំការខ្នុរ នាពេលនេះ គឺជាគុកសន្តិសុខរបស់ខ្មែរក្រហមនារបបប្រល័យពូជសាសន៏ ។

✦✦ ការសន្និដ្ឋានពីរណ្តៅសាកសព គុកសន្តិសុខ និងកន្លែងតំកល់អដ្ឋិធាតុ នៅស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ព្រមទាំងសាក្សី ។

ក/ រណ្តៅសាកសព មាន១កន្លែងគឺ

- នៅតំបន់ចំការខ្នុរ ក្នុងភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ក្នុងនោះមានរណ្តៅធំ១កន្លែងដែលមានបណ្តោយ ២០០ម៉ែត្រ និងទទឹង ៥ម៉ែត្រ ក្នុងមួយរណ្តៅនេះអាចដាក់សពបានចំនួនលើសពី ៥០០នាក់ ។ និងមានរណ្តៅតូចល្មមចំនួន ៤ទៀត ( នៅក្បែរៗគ្នា) ដែលមានទំហំ ៤ម៉ែត្រការ៉េ ។

- សាកសពដែលបានស្លាប់នៅទីនេះ មានប្រហែលពី ៤០០០ ទៅ ៥០០០នាក់

- ក្រោយថ្ងៃរំដោះរណ្តៅទាំងនេះ ត្រូវបានប្រជាជននាំគ្នាជីកកកាយរកមាស ដែលនៅជាប់ខ្លួនសាកសព ។ ប្រភេទជនរងគ្រោះ គឺមានលាយចំរុះគ្នា ។

ខ/ គុកសន្តិសុខរបស់ខ្មែរក្រហម មាន១កន្លែងគឺ

- នៅក្នុងទីធ្លាវត្តគីរីជុំចំការខ្នុរតែម្តង

- ទីតាំងវត្តស្ថិតនៅខាងកើតភ្នំស្វាយប្រហែល ១០០ម៉ែត្រ

- ប្រភេទជនរងគ្រោះ គឺមានលាយចំរុះគ្នា ដូចជា ( យួន, ចិន, ចាម, ខ្មែរ)

- ជាទីតាំងដែលគ្រាន់តែស្តុបអ្នកទោស ( មិនសម្លាប់ទេ)

គ/ កន្លែងតំកល់អដ្ឋិធាតុ

- ទីតាំងតំកល់អដ្ឋិធាតុ មានមួយកន្លែង គឺនៅក្នុងវត្តសុភមង្គល

- វត្តនេះស្ថិតនៅក្នុងភូមិ ឃុំអូរអំបិល ស្រុកសេរីសោភ័ណ

- អដ្ឋិធាតុ ត្រូវបានប្រមូលមកពីតំបន់ចំការខ្នុរ

- ស្តូបសំរាប់តំកល់អដ្ឋិធាតុគឺមានទំហំ ២,៥០ម៉ែត្រការ៉េ

ឃ/ សាក្សី

យើងមានសាក្សីយ៉ាងសំខាន់ៗចំនួនប្រាំនាក់ គឺលោក

- **ផាល់ សំអឿន** ជាប្រធានមន្ទីរពត៌មានស្រុកសេរីសោភ័ណ
- **អ៊ុក សឿន** ជាប្រធានផ្នែកវិទ្យុ-ទូរទស្សន៍ស្រុកសេរីសោភ័ណ
- **ស៊ី សុមិត្រ** ជាប្រធានរដ្ឋបាល ស្រុកសេរីសោភ័ណ

✦ មន្ត្រីទាំង ៣នាក់នេះ ជាអ្នកផ្តល់ពត៌មានយ៉ាងសំខាន់ពីការកាប់សម្លាប់មនុស្សនៅចំការខ្នុរ ដល់ក្រុមយើង ។

- ព្រះតេជគុណព្រះនាម **សៀន ញាណ** អាយុ ៦៩ឆ្នាំ គង់នៅវត្តសុភមង្គល ជាអ្នកបង្ហាញយើងពីកន្លែងតំកល់អដ្ឋិធាតុ និងជាអ្នកដែលបានជញ្ជូនអដ្ឋិធាតុទាំងនោះពីតំបន់ចំការខ្នុរ មកតំកល់ទុកនៅវត្តសុភមង្គលនេះ ។

- លោកតា **សោម ឡាច** អាយុ ៦៣ឆ្នាំ ជាគណៈកម្មការវត្តគីរីជុំចំការខ្នុរ ជាអ្នកបង្ហាញយើងពីរណ្តៅសាកសព នៅក្នុងចំការខ្នុរ ។

## II. ស្រុកភ្នំស្រុក

## ថ្ងៃព្រហស្បតិ៍ ទី២០ សីហា ១៩៩៨

ក្រុមស្រាវជ្រាវយើង បានស្រូតដំណើរពីព្រលឹមចេញពីស្រុកសេរីសោភ័ណឆ្ពោះទៅកាន់ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ នៅម៉ោង ៧:៥នាទី ។ ក្រុមយើងបានធ្វើដំណើរតាមផ្លូវជាតិ ....... គឺជាផ្លូវដែលឆ្ពោះទៅខេត្តសៀមរាប ។ ពីសាលាស្រុកសេរីសោភ័ណដល់សាលាស្រុកភ្នំស្រុកមានចំងាយ ៥១គីឡូម៉ែត្រ ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរត្រង់ពីស្រុកសេរីសោភ័ណមកដល់ភូមិព្រៃមាន់ ឃុំរហាល់ ស្រុកព្រះនេត្រព្រះ ក្នុងចំងាយ ៥៣គីឡូម៉ែត្រ ។ ការធ្វើដំណើររបស់យើងនាពេលនោះមានការលំបាកខ្លាំងណាស់ ព្រោះជារដូវវស្សា ដែលមានភ្លៀងធ្លាក់ស្ទើរតែរាល់ថ្ងៃ ហើយផ្លូវនោះជាផ្លូវលំដែលពោរពេញទៅដោយជង្ហុកជ្រៅៗ និងរអិលស្ទើរតែដើរមិនរួច ។ ពេលដែលយើងធ្វើដំណើរបានប្រហែល ៣២គីឡូម៉ែត្ររថយន្តរបស់យើងបានជាប់ផុងទៅមុខលែងរួច ប៉ុន្តែសំណាងដែរពេលនោះក្រុមយើងបានទៅជួលត្រាក់ទ័រ មួយមកអូសរថយន្តរបស់យើងអោយរួចពីកន្លែងជាប់នោះ ។ ក្រុមស្រាវជ្រាវយើងស្ទើរតែមិនហ៊ានបើក ភ្នែកមើលផ្លូវនោះផង ព្រោះគួរអោយញញើតខ្លាំងណាស់ ។ ក្រុមយើងចង់ត្រឡប់មកវិញ ប៉ុន្តែដោយ យើងមានសេចក្តីក្លាហាន ពុះពាររាល់ឧបសគ្គគ្រប់យ៉ាងទើបធ្វើអោយយើងបានមកដល់ផ្លូវបំបែកភូមិព្រៃ ហាន ឃុំរហាល់ (ផ្លូវបំបែកទៅខេត្តសៀមរាប និងចូលទៅកាន់ភ្នំស្រុក) ។ នៅពេលនោះ យើងបានសំរាក បន្តិចដើម្បីសំរួលឥរិយាបទ រួចចាប់ផ្តើមធ្វើដំណើរបន្តមកកាន់ស្រុកភ្នំស្រុក ក្នុងចំងាយ ១៦គីឡូម៉ែត្រ ទៀត ។

ផ្លូវពីភូមិព្រៃហនមកដល់សាលាស្រុកភ្នំស្រុក មានលក្ខណៈគ្រាន់បើ មិនសូវលំបាកណាស់ណាទេ, ការធ្វើដំណើររបស់យើងក៏មានការងាយស្រួលដែរ ។

នៅវេលាម៉ោង ៩:៣០នាទី នាថ្ងៃដដែល ក្រុមស្រាវជ្រាវយើងបានជួបជាមួយលោកអភិបាលស្រុកភ្នំស្រុកឈ្មោះ **គង់ ឈឿ** រស់នៅស្រុកព្រះនេត្រព្រះ កាលពីជំនាន់ **ប៉ុល ពត** ហើយបច្ចុប្បន្នរស់នៅភូមិស្រះជីក ឃុំស្រះជីក ស្រុកភ្នំស្រុក ។ យើងក៏បានជួបផងដែរជាមួយលោកអភិបាលស្រុករងឈ្មោះ **ឈុំ រួម** កាលពីជំនាន់ **ប៉ុល ពត** រស់នៅឃុំស្រះជីក ស្រុកសេរីសោភ័ណ ហើយបច្ចុប្បន្នក៏រស់នៅឃុំ ស្រុក ដដែលដែរ ។

ក្រោយពីបានស្តាប់ការឧទ្ទេសនាមរបស់ក្រុមស្រាវជ្រាវយើងរួច, លោកអភិបាលស្រុកទាំង២បានបញ្ជាក់ប្រាប់យើងពីស្ថានភាពស្រុករបស់លោក គឺស្រុកនេះមានព្រំប្រទល់ :

- ខាងកើត ជាប់នឹងស្រុកក្រឡាញ់ និងខេត្តបន្ទាយមានជ័យ
- ខាងលិច ជាប់នឹងស្រុកសេរីសោភ័ណ
- ខាងកើត ជាប់នឹងស្រុកថ្មពួក និងស្រុកបន្ទាយអំពិល
- ខាងត្បូង ជាប់នឹងស្រុកព្រះនេត្រព្រះ

ស្រុកនេះ - មាន ៥ឃុំ គឺឃុំស្រះជីក, ប៉ោយចារ, ស្ពានស្រែង, ណាំតៅ និងពន្លៃ

- មាន ៥០ភូមិ

- ចំនួនប្រជាជនមាន : ៨៦៧៣ គ្រួសារ
- ចំនួនមនុស្សរាយមាន : ៤៥០៧៦នាក់ ក្នុងនោះមានស្រី ២២.៦៧១នាក់
- ប្រជាជនមានសិទ្ធិបោះឆ្នោត : ២១.៨២៧នាក់
- ផ្ទៃដីរួម : ៧៤៣៦៥ ហិកតា
- ដីស្រែ : ១៧៩២០ ហិកតា, ក្រៅពីនេះជាដីព្រៃភ្នំ, លំនៅដ្ឋាន, បឹងបួរ និងដីមិនទាន់រុករាន
- មុខរបរប្រជាជនមាន ៩៨% ជាកសិករ ក្រៅពីនេះជាអ្នកនេសាទ, ធ្វើចំការ, ចិញ្ចឹមនាង ផលិតសរសៃសូត្រ

បន្ទាប់មកលោកអភិបាលស្រុកបានប្រាប់យើងថា ទីតាំងសាលាស្រុកពេលនេះជាអតីតគុកសន្តិសុខ នាសម័យ **ប៉ុល ពត** ហើយប្រភេទមនុស្សដែលជាប់ឃុំឃាំងនៅទីនោះ គឺមានលាយចំរុះគ្នា ដែលត្រូវបានប្រមូលមកពីគ្រប់ឃុំក្នុងទូទាំងស្រុកនេះ ។ លោកបានបន្តថា អ្នកជាប់ទោសទាំងអស់ ត្រូវបានខ្មែរក្រហមកោះអោយមកប្រជុំនៅវត្តជ្រៃឧត្តម ដើម្បីស្រាវជ្រាវរកចំនួនមនុស្សដែលមានចំណេះដឹង, អ្នក

បញ្ញវ័ន្ត, មន្ត្រីរាជការ ... អោយចុះឈ្មោះ ហើយពួកគេនឹងអនុញ្ញាតិអោយអ្នកទាំងនោះវិលទៅកាន់កន្លែង ដើមវិញ ។ ក្រោយពីជ្រើសរើសបានហើយ ពួកខ្មែរក្រហមក៏បានបញ្ជូអោយឡើងឡានដើម្បីវិលទៅ កន្លែងដើម, ប៉ុន្តែពួកខ្មែរក្រហមក៏បានដឹកយកអ្នកចេះដឹងទាំងនោះទៅសំលាប់ចោលនៅស្ពានត្បែង ដែលស្ថិតក្នុងភូមិព្រៃ ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យទាំងអស់ ក្នុងអំឡុងឆ្នាំ១៩៧៥-៧៦ លោកអភិបាលស្រុករង បានបញ្ជាក់ផងដែរថា មានអ្នកតំណាងរាស្ត្រម្នាក់ឈ្មោះ **ជូ ផុត** បានមកជាប់ឃុំនឹងគេដែរ ហើយត្រូវបានពួកខ្មែរក្រហមយកទៅបាញ់ចោលនៅដើមត្រមែង ស្ថិតក្នុងភូមិ និងឃុំស្រះជីក ស្រុកភ្នំស្រុកនេះ ។

ក្រោយពីក្រុមស្រាវជ្រាវយើងបានសួរពីទីតាំងសម្លាប់សំខាន់ៗរួចនោះ លោកអភិបាលស្រុកទាំងពីរ បានប្រាប់យើងថា នៅក្នុងស្រុកភ្នំស្រុក មានទីតាំងសម្លាប់ធំៗចំនួនបីកន្លែង គឺនៅព្រៃគោកត្រាច, គោកតាមុល និងនៅអាងត្រពាំងថ្ម ។

ក្រោយពីបានដឹងនូវពតិមានខាងលើ និងបន្ទាប់ពីបានចុះសួរ និងរកសាក្សីនៅតាមកន្លែងខាងលើរួចទើបដឹងថា :

**ក/ ព្រៃគោកត្រាច**

ព្រៃគោកត្រាចស្ថិតក្នុងឃុំគោកត្រាច ស្រុកភ្នំស្រុក មានចំងាយ ១៥០០ ម៉ែត្រ ពីសាលាស្រុកភ្នំស្រុក ។ ហើយនៅទីនោះមានដើមពោធិមួយដើមសំរាប់សំគាល់ថា ជាកន្លែងសម្លាប់យ៉ាងរង្គាលនាសម័យនោះ ។ ក្រុមស្រាវជ្រាវយើងបានចុះសួរផ្ទាល់ដល់ប្រជាជន ដែលរស់នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុកផ្ទាល់ ក្នុងនោះលោកយាយឈ្មោះ **ថន** បានប្រាប់យើងថា ក្នុងតំបន់គោកត្រាចនេះ មានការសម្លាប់មនុស្សយ៉ាងច្រើន ដែលត្រូវបានយកមកពីភូមិនានា ក្នុងឃុំប៉ោយចារនេះ ។ លោកយាយក៏បានបញ្ជាក់ផងដែរថា ការសម្លាប់នាពេលនោះ គឺមានសម្លាប់ទាំងគ្រួសារផង ។ នាពេលនោះលោកយាយ **ថន** បានសុខចិត្តធ្វើសាក្សីក្នុងការសម្លាប់មនុស្ស នៅក្នុងតំបន់ព្រៃគោកត្រាចនេះ ។ ចំពោះការប៉ាន់ស្មានមនុស្សដែលបានស្លាប់នៅទីនោះ លោកយាយព្រមទាំងលោកអភិបាលរងមិនអាចប៉ាន់ស្មានបានទេ គ្រាន់តែ បានបញ្ជាក់ថា មនុស្សដែលបានស្លាប់នៅព្រៃគោកត្រាចនេះ មានចំនួនច្រើន ។ ហើយនៅពេលដែលក្រុម ស្រាវជ្រាវយើងសួររកចំនួនរណ្តៅនោះ លោកអភិបាលស្រុករង បានបញ្ជាក់ថាគ្មានលក្ខណៈជារណ្តៅទេ ព្រោះពេលនោះពួកខ្មែរក្រហមបានត្រឹមតែវាយសម្លាប់ចោលៗ ប៉ុណ្ណោះ ។

**ខ/ តំបន់គោកតាមុល**

តំបន់នេះស្ថិតក្នុងឃុំស្រះជីក (ជាប់ខាងកើត ឆៀងខាងជើងភូមិគោកតារាជ) ស្រុកភ្នំស្រុក ។ ហើយមានចំងាយ ២គីឡូម៉ែត្រ ពីសាលាស្រុកភ្នំស្រុក ។

ដោយពេលវេលាមិនអំណោយផល ម្យ៉ាងទៀតក្រុមស្រាវជ្រាវយើងដែលចុះមកធ្វើការមានរយៈ ពេលខ្លី ដូច្នេះយើងបានសម្រេចចិត្តថា មិនបានចុះទៅផ្ទាល់ទេ ។ ចំនែកឯការសាកសួរពតិមានវិញ ក៏មិន បានដឹងដែរ ព្រោះលោកអភិបាលស្រុកទាំងពីរ មិនបានជ្រាបច្បាស់លាស់ ។

## ឆ/ នៅអាងទឹកត្រពាំងថ្ម

តំបន់អាងទឹកត្រពាំងថ្ម ស្ថិតនៅក្នុងភូមិត្រពាំងថ្មកណ្តាល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ហើយមាន ចំងាយ ៥គីឡូម៉ែត្រ និង ៩០០ម៉ែត្រ ពីសាលាស្រុក ។ សូមបញ្ជាក់ផងដែរថា ក្រោយពីបានសម្ភាសន៍ជា មួយលោកអភិបាលស្រុកទាំងពីររួចមក យើងក៏បានធ្វើដំណើរឆ្ពោះទៅកាន់តំបន់ត្រពាំងថ្មតែម្តង ។ ក្នុង ការធ្វើដំណើរនាម៉ោង ១០:១១នាទី របស់យើងនាពេលនោះ គឺមានការលំបាកខ្លាំងណាស់ សូម្បីតែលោក អភិបាលស្រុករង ដែលបានអញ្ជើញចូលរួមដំណើរជាមួយយើងក្នុងពេលនោះ ក៏បានស្ងើចសរសើរដល់ក្រុម យើងផងដែរ ថាពិតជាមានឧត្តមគតិមែន ។ ពិតមែនហើយ! បើគិតពីផ្លូវរអិល ក្រហេងក្រហូង ដាច់ដុំៗ យើងពិតជាមិនគួរធ្វើដំណើរទៅទេ ប៉ុន្តែដោយមានការក្លាហាន ហ៊ានពុះពាររាល់ឧបសគ្គ ទើបធ្វើអោយ យើងសម្រេចចិត្តភ្លាមៗថា ត្រូវតែធ្វើដំណើរទៅមុខរហូតដល់គោលដៅ ។ ប៉ុន្តែមុននឹងទៅដល់គោលដៅ រថយន្តរបស់យើងបានជាប់ផុង នៅចំណុចក្បែរអាងទឹកត្រពាំងថ្មនោះ អស់រយៈពេលជិតមួយម៉ោង ។ នៅ ពេលដែលរថយន្តយើងជាប់ផុង ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរដោយថ្មើរជើងឆ្ពោះទៅអាងត្រពាំងថ្ម ដែលជាទីតាំងសម្លាប់ធំជាងគេក្នុងទូទាំងស្រុក ។ ចំងាយពីរថយន្តជាប់ផុង ទៅអាងត្រពាំងថ្ម មានចំងាយ ប្រហែល៣០០ម៉ែត្រ ។ ពេលដែលយើងបានទៅដល់អាងនោះ លោកអភិបាលស្រុករងបានមានប្រសាសន៍ ប្រាប់យើងថា អាងនេះបានចាប់ផ្តើមជីកនៅឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៦ ដែលមានបណ្តោយ ១០ គីឡូម៉ែត្រ និងទទឹង ៧គីឡូម៉ែត្រ ហើយអាចផ្ទុកទឹកបានចំនួន ប្រាំពីរលានម៉ែត្រគីប ដើម្បីស្តុបទឹកសំរាប់ ធ្វើស្រែប្រាំងក្នុងស្រុកពីរ គឺស្រុកព្រះនេត្រព្រះ និងស្រុកភ្នំស្រុក ។ លោកបានបន្តទៀតថា អាងទឹកនេះ ត្រូវបានពួកខ្មែរក្រហមប្រមូលប្រជាជនពីស្រុកថ្មពួក, ស្រុកសេរីសោភ័ណ និងស្រុកព្រះនេត្រព្រះ ជាពិ

សេសប្រជាជនដែលរស់នៅទូទាំងតំបន់ ៥ អោយមកជីក ។ ក្នុងចំណោមប្រជាជនដែលបានមកជីកអាងនេះ ភាគច្រើនគឺជាយុវជន យុវនារី ព្រមទាំងប្រជាជនដែលទើបតែជំលៀសមកពីភ្នំពេញផង ។

នៅពេលដែលយើងសួរថា តើមានប្រជាជនស្លាប់នៅទីនេះប៉ុន្មាននាក់នោះ លោកអភិបាលរងស្រុក បានបញ្ជាក់ថា លោកមិនអាចកំណត់ចំនួនមនុស្សស្លាប់ក្នុងអាងនេះបានទេ ប៉ុន្តែលោកបានប៉ាន់ស្មានថា ប្រហែលជាមានមនុស្សស្លាប់នៅទីនេះ រាប់ពាន់នាក់ ហើយការស្លាប់របស់ពួកគេគឺមានទាំងការសម្លាប់ និងមានទាំងការអត់ឃ្លាន រហូតដល់ស្លាប់ផង ។ ចំណែកឯលោក **តាន់ មិញ** ជាប្រជាជនរស់នៅភូមិ ប៉ោយស្នួល ឃុំប៉ោយចារ ក៏បានបញ្ជាក់ផងដែរថា នៅក្នុងអាងទឹកនេះក៏មានរណ្តៅសំរាប់កប់សាកសព មួយចំនួនដែរ ប៉ុន្តែមានជាលក្ខណៈទ្រង់ទ្រាយតូច ហើយចំពោះអ្នកដែលបានស្លាប់នៅទីនោះ លោក **តាន់ មិញ** ក៏បានប្រាប់ដែរថា មានរាប់ពាន់នាក់ ដូចលោកអភិបាលស្រុករង បានបញ្ជាក់ដែរ ។ រីឯ លោក **តាត់ ឈឿម** រស់នៅភូមិ ឃុំ ស្រុកជាមួយលោក **តាន់ មិញ** ក៏បានបញ្ជាក់ដូចលោក **តាន់ មិញ** និងលោកអភិបាលស្រុករងដែរ ហើយម្យ៉ាងទៀត ក្រុមស្រាវជ្រាវយើងក៏មានសេចក្តីសោមនស្សរីករាយណាស់ដែរ នៅពេលដែលលោកអភិបាលស្រុករងឈ្មោះ **ឈុំ រួម** លោក **តាន់ មិញ** និងលោក **តាត់ ឈឿម** បានសុខចិត្តធ្វើជាសាក្សីក្នុងព្រឹត្តិការណ៍សម្លាប់មនុស្សក្នុងអាងទឹកត្រពាំងថ្មនេះ ។

នៅវេលាម៉ោង ១២:៤៥នាទី ក្រុមស្រាវជ្រាវយើងបានបន្តដំណើរឆ្ពោះទៅកាន់វត្តកណ្តាល ដែលស្ថិតនៅភូមិស្រះឈូក ឃុំស្រះជីកទៀត ដើម្បីពិនិត្យមើលស្តូបមួយដែលផ្ទុកពេញទៅដោយអដ្ឋិធាតុ ដែល បានប្រមូលមកពីកន្លែងសម្លាប់នានាក្នុងទូទាំងស្រុកភ្នំស្រុក ។ វត្តកណ្តាលនេះស្ថិតនៅចំងាយប្រហែល ៥០០ម៉ែត្រ ពីទីរួមស្រុក ។

✦✦ ការសន្និដ្ឋានពីរណ្តៅសាកសព គុកសន្តិសុខ និងកន្លែងតំកល់អដ្ឋិធាតុ នៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ព្រមទាំងសាក្សី :

នៅក្នុងទូទាំងស្រុកភ្នំស្រុក មានការកាប់សម្លាប់មនុស្សដែលមានទ្រង់ទ្រាយធំ មាន ៣កន្លែង, គុកសន្តិសុខ១កន្លែង និងកន្លែងតំកល់អដ្ឋិធាតុ១កន្លែង ។

① ទីតាំងសម្លាប់នៅព្រៃគោកត្រាច

- ស្ថិតនៅចំងាយ ១៥០០ម៉ែត្រ ពីសាលាស្រុក
- មានដើមពោធិមួយដើមសំរាប់សំគាល់
- មានការសម្លាប់យ៉ាងច្រើន, មានទាំងគ្រួសារផង

- ការប៉ាន់ស្មានមនុស្សដែលបានស្លាប់ : មានចំនួនច្រើន ( មិនអាចប៉ាន់ស្មានបាន)
- ប្រភេទជនរងគ្រោះលាយចំរុះ មានប្រជាជន, ទាហ៊ាន ដែលត្រូវឱ្យទៅទទួលសម្តេចឪ....
- គ្មានលក្ខណៈជារណ្តៅទេ

② **ទីតាំងគោកតាមុល**

- ស្ថិតនៅចំងាយ ២គីឡូម៉ែត្រ ពីសាលាស្រុក
- ក្រុមស្រាវជ្រាវយើងមិនបានចុះទៅទេ ហើយក៏គ្មានពត៌មានដែរ ព្រោះមានការលំបាកធ្វើដំណើរ ។

③ **ទីតាំងអាងទឹកត្រពាំងថ្ម**

- ស្ថិតនៅចំងាយ ៥គីឡូម៉ែត្រ និង ៩០០ម៉ែត្រ ពីសាលាស្រុក
- ចាប់ផ្តើមកសាងពីដើមឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ ១៩៧៦
- ប្រភេទជនរងគ្រោះ ច្រើនតែយុវជន យុវនារី អ្នកជំលៀសពីភ្នំពេញ
- ការប៉ាន់ស្មានចំនួនមនុស្សដែលស្លាប់ រាប់ពាន់នាក់
- ការស្លាប់របស់ពួកគេមាន ២ប្រភេទគឺត្រូវបានខ្មែរក្រហមសម្លាប់

និងស្លាប់ដោយអត់អាហារ រួមជាមួយការធ្វើទណ្ឌកម្មផង ។

- មានរណ្តៅសាកសពមួយចំនួន( មិនអាចរាប់បានព្រោះនៅក្នុងទឹក) ដែលមានទ្រង់ទ្រាយតូច

④ **ទីតាំងគុកសន្តិសុខ**

- ស្ថិតនៅក្នុងបរិវេណសាលាស្រុកភ្នំស្រុក នាពេលបច្ចុប្បន្ន
- ប្រភេទជនរងគ្រោះ លាយចំរុះគ្នា

⑤ **សាក្សី**

នៅក្នុងស្រុកភ្នំស្រុកយើងមានសាក្សីសំខាន់ៗមួយចំនួនដូចជា :

- លោក **ឈុំ រួម** ជាអភិបាលស្រុក បានផ្តល់ពត៌មាន និងចុះផ្ទាល់ដល់ទីតាំង
- លោក **តាត់ ឈឿម** ជាប្រជាជនរស់នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ

ជាអ្នកឃើញជាក់ ស្តែងក្នុងការសម្លាប់

និងប្រើទណ្ឌកម្មមកលើប្រជាជនដែលបានជីកអាងត្រពាំងថ្ម ។

- ឈ្មោះ **តាន់ មិញ** ជាប្រជាជនរស់នៅ ភូមិប៉ោយស្នួល ឃុំប៉ោយចារ ជាអ្នកបានឃើញ និងបានប្រាប់យើងថា មានរណ្តៅខ្លះៗនៅក្នុងអាងទឹក ។

- លោកយាយ **ឌន** ជាប្រជាជនរស់នៅ ភូមិប៉ោយស្នួល ឃុំប៉ោយចារ ជាអ្នកបានឃើញ នូវការសម្លាប់មនុស្សនៅព្រៃគោកត្រាច ។

## ខេត្តបន្ទាយមានជ័យ
## ថ្ងៃពុធ ទី១៩ ខែសីហា ឆ្នាំ១៩៩៨

នៅព្រឹកព្រលឹមថ្ងៃពុធទី១៩ ខែសីហា ឆ្នាំ១៩៩៨ វេលាម៉ោង ៦:៤៥នាទី ក្រុមស្រាវជ្រាវយើងបានចេញដំណើរពីខេត្តបាត់ដំបងឆ្ពោះទៅខេត្តបន្ទាយមានជ័យក្នុងចំងាយផ្លូវ ......... គីឡូម៉ែត្រ ។ ក្នុងការធ្វើដំណើររបស់ក្រុមស្រាវជ្រាវយើងនេះ គឺមានលក្ខណៈពិបាកណាស់ ព្រោះផ្លូវដែលយើងធ្វើដំណើរនោះមានសភាពចាស់ទ្រុឌទ្រោម, ដាច់ក្រហែងក្រហូងស្ទើរតែបើកបរពុំរួច ម្យ៉ាងទៀតជារដូវវស្សាផង ដែលជាហេតុធ្វើអោយកាន់តែមានការលំបាកទ្វេរឡើង ដោយផ្លូវរអិល ។ ដូច្នេះការធ្វើដំណើររបស់យើងត្រូវប្រើពេលអស់ពីរម៉ោងកន្លះ ។

នៅវេលាម៉ោង ៩:១០នាទី ក្រុមយើងបានទៅដល់សាលាខេត្តបន្ទាយមានជ័យ បន្ទាប់មកយើងបានជួបលោកអភិបាលរងទី៣ ខេត្ត ឈ្មោះ **អ៊ុំ ប៊ុន** ដើម្បីទំនាក់ទំនងសំណុំបែបបទរដ្ឋបាល ។ បន្ទាប់មកលោកអភិបាលរង បានបញ្ជូអោយបុគ្គលិករដ្ឋបាលម្នាក់ធ្វើលិខិតជាផ្លូវការមួយ ដោយបានឯកភាព និងយល់ព្រមអោយក្រុមស្រាវជ្រាវយើងចុះទៅតាមបណ្តាស្រុកនានាក្នុងទូទាំងខេត្ត ។

ខេត្តបន្ទាយមានជ័យមានព្រំប្រទល់ :

- ខាងជើង និងខាងលិច ជាប់នឹងប្រទេសថៃ ប្រវែង ២៦៨គីឡូម៉ែត្រ
- ខាងកើត និងខាងត្បូង ជាប់នឹងខេត្តបាត់ដំបង និងខេត្តសៀមរាប
- ចំនួនផ្ទៃដីរួម : ៧.៨៦៥ គីឡូម៉ែត្រការ៉េ
- ផ្ទៃដីបង្កបង្កើនផល : ២.៤៥៥,៥ គីឡូម៉ែត្រការ៉េ
- ផ្ទៃដីព្រៃ : ៤.៥៨៤,៥ គីឡូម៉ែត្រការ៉េ
- ផ្ទៃដីស្មឹងបឹងបួរ : ៩០៥ គីឡូម៉ែត្រការ៉េ
- ផ្ទៃដីលំនៅដ្ឋាន : ១៣០ គីឡូម៉ែត្រការ៉េ
- ចំនួនប្រជាជនរួម : ៥៧៧.៧៣៣ នាក់

  ក្នុងនោះមានស្រី : ២៨៩.៤២៣ នាក់

- មាន៩ស្រុក គឺស្រុកសេរីសោភ័ណ, មង្គលបុរី, អូរជ្រៅ, ព្រះនេត្រព្រះ, ភ្នំស្រុក, ស្វាយចេក, ថ្មពួក, បន្ទាយអំពិល និងស្រុកម៉ាឡៃ ។

- មាន ៦៥ឃុំ ដែលទទួលស្គាល់ដោយអនុក្រិត្យ និងឃុំចំនួន៣ ដែលសុំបង្កើតថ្មី ។

- មាន ៩៦៩ភូមិ ដែលទទួលស្គាល់ដោយអនុក្រិត្យ និងភូមិចំនួន ៨៤ ដែលសុំបង្កើតថ្មី

ក្រោយពីបានជួបសំណេះសំណាល និងបំពេញបែបបទរដ្ឋបាលជាមួយឯកឧត្តមអភិបាលរងទី៣ ខេត្តរួច យើងក៏បានធ្វើដំណើរទៅកាន់ស្រុកមួយចំនួនដែលយើងចង់ទៅ ។

## I. ស្រុកសេរីសោភ័ណ

នាពេលនេះ ក្រុមអ្នកស្រាវជ្រាវយើងមិនបានជួបលោកអភិបាលស្រុកទេ ព្រោះពេលនោះគាត់ជាប់រវល់ត្រូវចេញទៅខាងក្រៅ ដើម្បីទំនាក់ទំនងការងារផ្សេងៗ ដោយពេលវេលាចេះតែរំកិលទៅមុខក្រុមស្រាវជ្រាវយើងមិនអាចនៅរង់ចាំលោកអភិបាលស្រុកបានទេ ដូច្នេះយើងបានធ្វើដំណើរត្រឡប់មកកាន់មន្ទីរព័ត៌មានស្រុកវិញ ។

នៅវេលាម៉ោង ១០:១៨នាទី នាថ្ងៃដដែល ក្រុមស្រាវជ្រាវយើងបានមកជួបជាមួយលោក **បាល់ សំអឿន** ជាប្រធានមន្ទីរព័ត៌មានស្រុកសេរីសោភ័ណ ។ ក្នុងពេលជួបជាមួយលោក **បាល់ សំ អឿន** នោះ យើងក៏បានជួបជាមួយសហការីរបស់លោកចំនួនពីរនាក់ទៀត គឺលោក **អ៊ុក សឿន** ប្រធានផ្នែកទូរទស្សន៍-វិទ្យុ និងលោក **ស៊ី សុមិត្រ** ជាប្រធានរដ្ឋបាល ។

លោកប្រធានមន្ទីរបានប្រាប់យើងថា ក្នុងស្រុកសេរីសោភ័ណនេះ មានទីតាំងសម្លាប់មួយធំជាង គេ គឺនៅតំបន់ចំការខ្នុរ ដែលស្ថិតនៅខាងជើងវត្តគីរីជុំ ចំការខ្នុរ និងភ្នំស្វាយ ។ តំបន់នេះស្ថិតនៅក្នុងភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ លោកបានបន្តថា នៅទីនោះសព្វថ្ងៃនៅមានស្នាកស្នាមបន្សល់ទុកដូចជារណ្ដៅធំៗដែលលុបមិនជិតជាដើម ។ កាលពីទើបតែរំដោះថ្មីៗ រណ្ដៅដែលកប់សាកសពនេះ ត្រូវបានប្រជាជនក្នុងភូមិ ឃុំ ខាងលើ ជីកកកាយ និងឆែកឆេរខ្លួនរបស់សាកសពដើម្បីរកមាស និងគ្រឿងអលង្ការផ្សេងៗ ដែលធ្វើឲ្យសាកសពទាំងនោះហាក់លេចចេញនៅលើដីក្នុងរណ្ដៅ ព្រោះក្រោយពីឆែកឆេររួច ប្រជាជនទាំងនោះមិនបានកប់វិញទេ ។ តាមប្រសាសន៍របស់លោក កាន់ ឈឿន ប្រាប់ទៅអ្នកយកព័ត៌មានកាសែតរស្មីកម្ពុជា ហើយដែល ឡាយុំ បានយកមកចុះផ្សាយនៅក្នុងទំព័រកាសែតដដែលនេះលេខ ៤១២៥ ចេញផ្សាយថ្ងៃអាទិត្យ-ច័ន្ទ ទី៥-៦ វិច្ឆិកា ឆ្នាំ២០០៦ ថាការគាស់រណ្ដៅសាកសពនៅវាលពិឃាតចម្ការខ្នុរនេះ ក៏មានការចូលរួមពីសំណាក់ប្រជាជនមួយចំនួនដែលស្នាក់នៅបណ្ដោះអាសន្ននៅវត្តសុភមង្គលដែរ ព្រោះថាជាការស្នើសុំរបស់ព្រះចៅអធិការវត្តសុភមង្គល់ ។ កាសែតដដែលបានបន្តថា សឿន និងប្រពន្ធឈ្មោះ បឿន ជាអ្នកដែលគាស់បានឆ្អឹងខ្មោចច្រើនជាងគេ ។ លោក **អ៊ុក សឿន** ប្រធានវិទ្យុ និង

ទូរទស្សន៍បានបញ្ជាក់ថា ក្នុងរណ្ដៅធំមួយៗមានសាកសពរាប់រយនាក់ ។ លោកបានបន្តថា ចំនួនសាកសពទាំងអស់ក្នុងវាលពិឃាតចំការខ្នុរនេះមានប្រហែលពី៤០០០ទៅ៥០០០នាក់ ។ ចំណែកលោក ឈួន បុណ្យ ជាអាចារ្យវត្តសុភមង្គល ស្រុកសិរីសោភ័ណ ក៏បានឲ្យដឹងតាមរយៈកាសែតរស្មីកម្ពុជាដែរថា ជនរងគ្រោះរាប់ពាន់នាក់ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់នៅក្នុងបរិវេណដីច្រើនហិកតានៃបរិវេណវត្តជុំគិរីចម្ការខ្នុរ រហូតដល់ត្រង់មុំមណ្ឌលអន្តការកុមារកម្ពុជា ។ លោក **ស៊ី សុមិត្រ** ក៏បានបញ្ជាក់ផងដែរថា អដ្ឋិធាតុភាគច្រើននៃសាកសពទាំងនោះ ត្រូវប្រជាជនក្នុងភូមិអូរអំបិលដឹកជញ្ជូនយកមកតំកល់ទុកនៅវត្តសុភមង្គល ដែលស្ថិតនៅក្នុងភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ។

ក្រោយពីបានបរិយាយប្រាប់អ្នកស្រាវជ្រាវយើងរួច លោកទាំង៣ បានសុខចិត្តធ្វើជាសាក្សី និងធានាថាអ្វីដែលលោកទាំងបី បាននិយាយនោះ សុទ្ធសឹងតែជាការពិត និងបានឃើញផ្ទាល់ភ្នែក ។

នៅម៉ោង ១១:០២នាទី បន្ទាប់ពីក្រុមស្រាវជ្រាវយើង បានដឹងពត៌មានពីមន្ត្រីស្រុកសេរីសោភ័ណរួច យើងក៏ប្រញាប់ប្រញាល់ធ្វើដំណើរមកកាន់វត្តសុភមង្គលភ្លាម ដើម្បីចុះទៅពិនិត្យផ្ទាល់នូវស្តូបមួយដែលតំកល់អដ្ឋិធាតុប្រជាជនដែលបានស្លាប់ក្នុងរបបផ្តាច់ការប្រល័យពូជសាសន៍ ។ មិនតែប៉ុណ្ណោះ យើងបានទៅជួបលោកគ្រូសូត្រវត្តសុភមង្គលព្រះនាម **សៀន ញាណ** ព្រះជន្ម៦៩ព្រះវស្សាទៀត ព្រះអង្គបានគូសបញ្ជាក់ប្រាប់យើងថា នៅចំការខ្នុរនេះមានការសម្លាប់ទាំងខ្មែរៗ ហើយប្រភេទជនរងគ្រោះមានលាយចំរុះគ្នា ប៉ុន្តែភាគច្រើនគឺជាអនិកជនវៀតណាម ដែលបានមករស់នៅតាំងពីយូរយារណាស់មកហើយ ហើយអនិកជនចិន, ឡាវ និងចាម ក៏មានស្លាប់នៅទីនោះដែរ ។ ព្រះអង្គបានបន្តថា តាមការប៉ាន់ស្មានចំនួនមនុស្សដែលស្លាប់នៅចំការខ្នុរ នេះមានចំនួនពី ៤០០០ ទៅ ៤៥០០នាក់ ហើយចំពោះអដ្ឋិធាតុវិញ ត្រូវបានព្រះអង្គព្រះនាម **សៀន ញាណ** ផ្ទាល់តែម្តង ដែលជាអ្នកដឹកនាំប្រជាជនក្នុងភូមិអោយទៅដឹកយកមកដាក់តំកល់ក្នុងស្តូបនាវត្តសុភមង្គលនេះ ។ ព្រះអង្គបានបន្ថែមថា ការសម្លាប់មនុស្សនៅចំការខ្នុរនេះ គឺចាប់ផ្តើមនៅឆ្នាំ១៩៧៦ ហើយបន្តរហូតមកដល់ចុងឆ្នាំ១៩៧៨ ។ ព្រះអង្គបានប្រាប់ថា កាលពីជំនាន់ **ប៉ុល ពត** ព្រះអង្គរស់នៅឃុំសំរោង ស្រុកសេរីសោភ័ណ ហើយក្រោយថ្ងៃរំដោះព្រះអង្គបានវិលមករស់នៅឃុំអូរអំបិលវិញ ។

ដូច្នេះព្រះអង្គគ្រូសូត្រនៃវត្តសុភមង្គលឈ្មោះ **សៀន ញាណ** បានស្ម័គ្រចិត្តធ្វើសាក្សីក្នុងរឿងឧក្រិដ្ឋកម្មខាងលើរបស់ខ្មែរក្រហមមកលើប្រជាជនក្នុងភូមិ ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ។

ដោយស្ថានភាពនៅស្រុកសេរីសោភ័ណ មានលក្ខណៈល្អប្រសើរ ជាពិសេសនៅតំបន់ចំការខ្នុរ ក្នុងឃុំអូរអំបិលមានស្ថេរភាពល្អ អាចអោយក្រុមស្រាវជ្រាវយើងចុះទៅពិនិត្យផ្ទាល់បាន ទើបនៅវេលាម៉ោង

១២:៤៥នាទី យើងបានបន្តដំណើរចេញពីវត្តសុភមង្គលឆ្ពោះទៅកាន់តំបន់ចំការខ្នុរ ។ នាពេលនោះ យើងបានចូលទៅកាន់វត្តគីរីជុំចំការខ្នុរ ដែលមានចំងាយប្រហែល ៣គីឡូម៉ែត្រពីផ្លូវជាតិ និងនៅខាងកើតភ្នំស្វាយ ។ បន្ទាប់មកយើងបានជួបនឹងគណៈកម្មការវត្តម្នាក់ឈ្មោះ **សោម ឡាង** ដែលបានឃើញផ្ទាល់ភ្នែកនូវសកម្មភាពរបស់ប្រជាជនក្នុងការជីកកកាយរកមាស ហើយព្រមទាំងបានបញ្ជាក់ថា រណ្តៅសាកសពទាំងនេះ គឺជីកដោយត្រាក់ទ័រ ដែលរណ្តៅចំនួនមួយ ដែលធំជាងគេ គឺមានទទឹង ៥ម៉ែត្រ និងបណ្តោយ ២០០ម៉ែត្រ និងមានជំរៅ ១ម៉ែត្រ ហើយក្រៅពីនេះមានរណ្តៅបន្ទាប់បន្សំចំនួន ៤ទៀត ដែលមានទំហំប្រហែល ៤ម៉ែត្រការ៉េ ។ លោកតា **សោម ឡាង** បានប្រាប់យើងថា លោកមានអាយុ ៦៣ឆ្នាំ កាលពីសម័យ **ប៉ុល ពត** គាត់រស់នៅស្រុកមោង ខេត្តបាត់ដំបង ហើយក្រោយថ្ងៃរំដោះ គាត់ក៏បានមករស់នៅក្នុងភូមិ ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ពេលនោះលោកតា បានប៉ាន់ស្មានថាសាកសពដែលបានស្លាប់ក្នុងចំការខ្នុរនេះមានប្រហែលរាប់ពាន់អ្នក ព្រោះនៅក្នុងរណ្តៅដ៏ធំមួយនេះ អាចមានមនុស្សស្លាប់លើសពី ៥០០នាក់ ។

ទីតាំងតំបន់ចំការខ្នុរនេះស្ថិតនៅចំងាយប្រហែល ២០០ម៉ែត្រ ពីវត្តគីរីជុំចំការខ្នុរភាគខាងជើង និងមានចំងាយប្រហែល ២០០ម៉ែត្រ ដែលពីភ្នំស្វាយ ភាគខាងជើងដូចគ្នា ។ ហើយជាពិសេសទៅទៀតទីតាំងវត្តគីរីជុំចំការខ្នុរ នាពេលនេះ គឺជាគុកសន្តិសុខរបស់ខ្មែរក្រហមនារបបប្រល័យពូជសាសន៍ ។

ការសន្និដ្ឋានពីរណ្តៅសាកសព គុកសន្តិសុខ និងកន្លែងតំកល់អដ្ឋិធាតុ នៅស្រុកសេរីសោ ភ័ណខេត្តបន្ទាយមានជ័យ ព្រមទាំងសាក្សី ។

**ក) រណ្តៅសាកសព មាន១កន្លែងគឺ**

- នៅតំបន់ចំការខ្នុរ ក្នុងភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសេរីសោភ័ណ ក្នុងនោះមានរណ្តៅធំ១កន្លែងដែលមានបណ្តោយ ២០០ម៉ែត្រ និងទទឹង ៥ម៉ែត្រ ក្នុងមួយរណ្តៅនេះអាចដាក់សពបានចំនួនលើសពី ៥០០នាក់ ។ និងមានរណ្តៅតូចល្មមចំនួន ៤ទៀត (នៅក្បែរៗគ្នា) ដែលមានទំហំ ៤ម៉ែត្រការ៉េ ។
- សាកសពដែលបានស្លាប់នៅទីនេះ មានប្រហែលពី ៤០០០ ទៅ ៥០០០នាក់
- ក្រោយថ្ងៃរំដោះរណ្តៅទាំងនេះ ត្រូវបានប្រជាជននាំគ្នាជីកកកាយរកមាស ដែលនៅជាប់ខ្លួនសាកសព ។ ប្រភេទជនរងគ្រោះ គឺមានលាយចំរុះគ្នា ។

**ខ) គុកសន្តិសុខរបស់ខ្មែរក្រហម មាន១កន្លែងគឺ**

- នៅក្នុងទីធ្លាវត្តគីរីជុំចំការខ្នុរតែម្តង

- ទីតាំងវត្តស្ថិតនៅខាងកើតភ្នំស្វាយប្រហែល ១០០ម៉ែត្រ
- ប្រភេទជនរងគ្រោះ គឺមានលាយចំរុះគ្នា ដូចជា (យួន, ចិន, ចាម, ខ្មែរ)
- ជាទីតាំងដែលគ្រាន់តែស្តុបអ្នកទោស (មិនសម្លាប់ទេ)

**គ) កន្លែងតំកល់អដ្ឋិធាតុ**

- ទីតាំងតំកល់អដ្ឋិធាតុ មានមួយកន្លែង គឺនៅក្នុងវត្តសុភមង្គល
- វត្តនេះស្ថិតនៅក្នុងភូមិ ឃុំអូរអំបិល ស្រុកសេរីសោភ័ណ
- អដ្ឋិធាតុ ត្រូវបានប្រមូលមកពីតំបន់ចំការខ្មុរ
- ស្តូបសំរាប់តំកល់អដ្ឋិធាតុគឺមានទំហំ ២,៥០ម៉ែត្រការ៉េ

**ឃ) សាក្សី**

យើងមានសាក្សីយ៉ាងសំខាន់ៗចំនួនប្រាំនាក់ គឺលោក

- **ប៉ាល់ សំអឿន** ជាប្រធានមន្ទីរពត៌មានស្រុកសេរីសោភ័ណ
- **អ៊ុក សឿន** ជាប្រធានផ្នែកវិទ្យុ-ទូរទស្សន៍ស្រុកសេរីសោភ័ណ
- **ស៊ី សុមិត្រ** ជាប្រធានរដ្ឋបាល ស្រុកសេរីសោភ័ណ

មន្ត្រីទាំង ៣នាក់នេះ ជាអ្នកផ្តល់ពត៌មានយ៉ាងសំខាន់ពីការកាប់សម្លាប់មនុស្សនៅចំការខ្មុរ ដល់ក្រុមយើង ។

- ព្រះតេជគុណព្រះនាម **សៀន ញាណ** អាយុ ៦៩ឆ្នាំ គង់នៅវត្តសុភមង្គល ជាអ្នកបង្ហាញយើងពីកន្លែងតំកល់អដ្ឋិធាតុ និងជាអ្នកដែលបានជញ្ជូនអដ្ឋិធាតុទាំងនោះពីតំបន់ចំការខ្មុរ មកតំកល់ទុកនៅវត្តសុភមង្គលនេះ ។
- លោកតា **សោម ធ្បាខ** អាយុ ៦៣ឆ្នាំ ជាគណៈកម្មការវត្តគិរីជុំចំការខ្មុរ ជាអ្នកបង្ហាញយើងពីរណ្តៅសាកសព នៅក្នុងចំការខ្មុរ ។

## II. ស្រុកភ្នំស្រុក

### ថ្ងៃព្រហស្បតិ៍ ទី២០ សីហា ១៩៩៨

ក្រុមស្រាវជ្រាវយើង បានស្រូតដំណើរពីព្រលឹមចេញពីស្រុកសេរីសោភ័ណឆ្ពោះទៅកាន់ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ នៅម៉ោង ៧:៥នាទី ។ ក្រុមយើងបានធ្វើដំណើរតាមផ្លូវជាតិ ....... គឺជាផ្លូវដែលឆ្ពោះទៅខេត្តសៀមរាប ។ ពីសាលាស្រុកសេរីសោភ័ណដល់សាលាស្រុកភ្នំស្រុកមានចំងាយ ៥១គីឡូ

ម៉ែត្រ ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរត្រង់ពីស្រុកសេរីសោភ័ណមកដល់ភូមិព្រៃមាន់ ឃុំរហាល ស្រុកព្រះនេត្រព្រះ ក្នុងចំងាយ ៥៣គីឡូម៉ែត្រ ។ ការធ្វើដំណើររបស់យើងនាពេលនោះមានការលំបាកខ្លាំងណាស់ ព្រោះជារដូវវស្សា ដែលមានភ្លៀងធ្លាក់ស្ទើរតែរាល់ថ្ងៃ ហើយផ្លូវនោះជាផ្លូវលំដែលពោរពេញទៅដោយជង្ហុកជ្រៅៗ និងរអិលស្ទើរតែដើរមិនរួច ។ ពេលដែលយើងធ្វើដំណើរបានប្រហែល ៣២គីឡូម៉ែត្រ រថយន្តរបស់យើងបានជាប់ផុងទៅមុខលែងរួច ប៉ុន្តែសំណាងដែរ ពេលនោះក្រុមយើងបានទៅជួលត្រាក់ទ័រមួយមកអូសរថយន្តរបស់យើងអោយរួចពីកន្លែងជាប់នោះ ។ ក្រុមស្រាវជ្រាវយើងស្ទើរតែមិនហ៊ានបើកភ្នែកមើលផ្លូវនោះផង ព្រោះគួរអោយញញើតខ្លាំងណាស់ ។ ក្រុមយើងចង់ត្រឡប់មកវិញ ប៉ុន្តែដោយយើងមានសេចក្តីក្លាហាន ពុះពាររាល់ឧបសគ្គគ្រប់យ៉ាង ទើបធ្វើអោយយើងបានមកដល់ផ្លូវបំបែកភូមិព្រៃមាន់ ឃុំរហាល (ផ្លូវបំបែកទៅខេត្តសៀមរាប និងចូលទៅកាន់ភ្នំស្រុក) ។ នៅពេលនោះ យើងបានសំរាក បន្តិចដើម្បីសំរួលឥរិយាបទ រួចចាប់ផ្តើមធ្វើដំណើរបន្តមកកាន់ស្រុកភ្នំស្រុក ក្នុងចំងាយ ១៦គីឡូម៉ែត្រទៀត ។ ផ្លូវពីភូមិព្រៃហនមកដល់សាលាស្រុកភ្នំស្រុក មានលក្ខណៈគ្រាន់បើ មិនសូវលំបាកណាស់ណាទេ,ការធ្វើដំណើររបស់យើងក៏មានការងាយស្រួលដែរ ។

នៅវេលាម៉ោង ៩:៣០នាទី នាថ្ងៃដដែល ក្រុមស្រាវជ្រាវយើងបានជួបជាមួយលោកអភិបាលស្រុកភ្នំស្រុកឈ្មោះ **គង់ រស្មី** រស់នៅស្រុកព្រះនេត្រព្រះ កាលពីជំនាន់ **ប៉ុល ពត** ហើយបច្ចុប្បន្នរស់នៅភូមិស្រះជីក ឃុំស្រះជីក ស្រុកភ្នំស្រុក ។ យើងក៏បានជួបផងដែរជាមួយលោកអភិបាលស្រុករងឈ្មោះ **ឈុំ រួម** កាលពីជំនាន់ **ប៉ុល ពត** រស់នៅឃុំស្រះជីក ស្រុកសេរីសោភ័ណ ហើយបច្ចុប្បន្នក៏រស់នៅឃុំ ស្រុកដដែលដែរ ។

ក្រោយពីបានស្តាប់ការខទ្ទេសនាមរបស់ក្រុមស្រាវជ្រាវយើងរួច, លោកអភិបាលស្រុកទាំង២ បានបញ្ជាក់ប្រាប់យើងពីស្ថានភាពស្រុករបស់លោក គឺស្រុកនេះមានព្រំប្រទល់ :

- ខាងកើត ជាប់នឹងស្រុកក្រឡាញ់ និងខេត្តបន្ទាយមានជ័យ
- ខាងលិច ជាប់នឹងស្រុកសេរីសោភ័ណ
- ខាងកើត ជាប់នឹងស្រុកថ្មពួក និងស្រុកបន្ទាយអំពិល
- ខាងត្បូង ជាប់នឹងស្រុកព្រះនេត្រព្រះ

ស្រុកនេះ

- មាន ៥ឃុំ គឺឃុំស្រះជីក, ប៉ោយចារ, ស្ពានស្រែង, ណាំតៅ និងពន្លៃ
- មាន ៥០ភូមិ

- ចំនួនប្រជាជនមាន ៖ ៨៦៧៣ គ្រួសារ
- ចំនួនមនុស្សរាយមាន ៖ ៤៥០៧៦នាក់ ក្នុងនោះមានស្រី ២២.៦៧១នាក់
- ប្រជាជនមានសិទ្ធិបោះឆ្នោត ៖ ២១.៨២៧នាក់
- ផ្ទៃដីរួម ៖ ៧៤៣៦៥ ហិកតា
- ដីស្រែ ៖ ១៧៩២០ ហិកតា, ក្រៅពីនេះជាដីព្រៃភ្នំ, លំនៅដ្ឋាន, បឹងបួរ និងដីមិនទាន់រុករាន
- មុខរបរប្រជាជនមាន៩៨៖ ជាកសិករ ក្រៅពីនេះជាអ្នកនេសាទ, ផ្ទើចំការ, ចិញ្ចឹមទាផង ផលិតសរសៃសូត្រ

បន្ទាប់មកលោកអភិបាលស្រុកបានប្រាប់យើងថា ទីតាំងសាលាស្រុកពេលនេះជាអតីតគុកសន្តិសុខនាសម័យ **ប៉ុល ពត** ហើយប្រភេទមនុស្សដែលជាប់ឃុំឃាំងនៅទីនោះ គឺមានលាយចំរុះគ្នា ដែលត្រូវបានប្រមូលមកពីគ្រប់ឃុំក្នុងទូទាំងស្រុកនេះ ។ លោកបានបន្តថា អ្នកជាប់ទោសទាំងអស់ ត្រូវបានខ្មែរក្រហមកោះអោយមកប្រជុំនៅវត្តជ្រៃខត្តម ដើម្បីស្រាវជ្រាវរកចំនួនមនុស្សដែលមានចំណេះដឹង, អ្នកបញ្ញវ័ន្ត, មន្ត្រីរាជការ ... អោយចុះឈ្មោះ ហើយពួកគេនឹងអនុញ្ញាតិអោយអ្នកទាំងនោះវិលទៅកាន់កន្លែងដើមវិញ។ ក្រោយពីជ្រើសរើសបានហើយ ពួកខ្មែរក្រហមក៏បានបញ្ជូនអោយឡើងឡានដើម្បីវិលទៅកន្លែងដើម, ប៉ុន្តែពួកខ្មែរក្រហមក៏បានដឹកយកអ្នកចេះដឹងទាំងនោះទៅសំលាប់ចោលនៅស្ពានត្បែង ដែលស្ថិតក្នុងភូមិព្រៃ ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យទាំងអស់ ក្នុងអំឡុងឆ្នាំ១៩៧៥-៧៦ លោកអភិបាលស្រុករង បានបញ្ជាក់ផងដែរថា មានអ្នកតំណាងរាស្ត្រម្នាក់ឈ្មោះ **ឡូ ផុត** បានមកជាប់ ឃុំនឹងគេដែរ ហើយត្រូវបានពួកខ្មែរក្រហមយកទៅបាញ់ចោលនៅដើមត្រមែង ស្ថិតក្នុងភូមិ និងឃុំស្រះជីក ស្រុកភ្នំស្រុកនេះ ។

ក្រោយពីក្រុមស្រាវជ្រាវយើងបានសួរពីទីតាំងសម្លាប់សំខាន់ៗរួចនោះ លោកអភិបាលស្រុកទាំងពីរបានប្រាប់យើងថា នៅក្នុងស្រុកភ្នំស្រុក មានទីតាំងសម្លាប់ធំៗចំនួនបីកន្លែង គឺនៅព្រៃគោកគ្រាច, គោកតាមុល និងនៅអាងត្រពាំងថ្ម ។

ក្រោយពីបានដឹងនូវពត៌មានខាងលើ និងបន្ទាប់ពីបានចុះសួរ និងរកសាក្សីនៅតាមកន្លែងខាងលើរួចទើបដឹងថា ៖

## ក) ព្រៃគោកគ្រាច

ព្រៃគោកគ្រាចស្ថិតក្នុងឃុំគោកគ្រាច ស្រុកភ្នំស្រុក មានចំងាយ ១៥០០ ម៉ែត្រ ពីសាលាស្រុកភ្នំស្រុក ។ ហើយនៅទីនោះមានដើមពោធិមួយដើមសំរាប់សំគាល់ថា ជាកន្លែងសម្លាប់យាំងវគ្គលនាសម័យ

នោះ ។ ក្រុមស្រាវជ្រាវយើងបានចុះសួរផ្ទាល់ដល់ប្រជាជន ដែលរស់នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ស្រុកភ្នំស្រុកផ្ទាល់ ក្នុងនោះលោកយាយឈ្មោះ **ចន** បានប្រាប់យើងថា ក្នុងតំបន់គោកគ្រាចនេះ មានការសម្លាប់មនុស្សយ៉ាងច្រើន ដែលត្រូវបានយកមកពីភូមិនានា ក្នុងឃុំប៉ោយចារនេះ ។ លោកយាយក៏បានបញ្ជាក់ផងដែរថា ការសម្លាប់នាពេលនោះ គឺមានសម្លាប់ទាំងគ្រួសារផង ។ នាពេលនោះលោកយាយ **ចន** បានសុខចិត្តធ្វើសាក្សីក្នុងការសម្លាប់មនុស្ស នៅក្នុងតំបន់ព្រៃគោកគ្រាចនេះ ។ ចំពោះការប៉ាន់ស្មានមនុស្សដែលបានស្លាប់នៅទីនោះ លោកយាយព្រមទាំងលោកអភិបាលរងមិនអាចប៉ាន់ស្មានបានទេ គ្រាន់តែបានបញ្ជាក់ថា មនុស្សដែលបានស្លាប់នៅព្រៃគោកគ្រាចនេះ មានចំនួនច្រើន ។ ហើយនៅពេលដែលក្រុមស្រាវជ្រាវយើងសួររកចំនួនរណ្តៅនោះ លោកអភិបាលស្រុករង បានបញ្ជាក់ថា គ្មានលក្ខណៈជារណ្តៅទេ ព្រោះពេលនោះពួកខ្មែរក្រហមបានត្រឹមតែវាយសម្លាប់ចោលៗ ប៉ុណ្ណោះ ។

**ខ) តំបន់គោកតាមុល**

តំបន់នេះស្ថិតក្នុងឃុំស្រះជីក (ជាប់ខាងកើត ឆៀងខាងជើងភូមិគោកតារាជ) ស្រុកភ្នំស្រុក ។ ហើយមានចំងាយ ២គីឡូម៉ែត្រ ពីសាលាស្រុកភ្នំស្រុក ។

ដោយពេលវេលាមិនអំណោយផល ម្យ៉ាងទៀតក្រុមស្រាវជ្រាវយើងដែលចុះមកធ្វើការមានរយៈពេលខ្លី ដូច្នេះយើងបានសម្រេចចិត្តថា មិនបានចុះទៅផ្ទាល់ទេ ។ ចំណែកឯការសាកសួរព័ត៌មានវិញ ក៏មិនបានដឹងដែរ ព្រោះលោកអភិបាលស្រុកទាំងពីរ មិនបានជ្រាបច្បាស់លាស់ ។

**គ) នៅអាងទឹកត្រពាំងថ្ម**

តំបន់អាងទឹកត្រពាំងថ្ម ស្ថិតនៅក្នុងភូមិត្រពាំងថ្មកណ្តាល ឃុំប៉ោយចារ ស្រុកភ្នំស្រុក ហើយមានចំងាយ ៥គីឡូម៉ែត្រ និង ៩០០ម៉ែត្រ ពីសាលាស្រុក ។ សូមបញ្ជាក់ផងដែរថា ក្រោយពីបានសម្ភាសន៍ជាមួយលោកអភិបាលស្រុកទាំងពីររួចមក យើងក៏បានធ្វើដំណើរឆ្ពោះទៅកាន់តំបន់ត្រពាំងថ្មតែម្តង ។ ក្នុង ការធ្វើដំណើរនាម៉ោង ១០:១១នាទី របស់យើងនាពេលនោះ គឺមានការលំបាកខ្លាំងណាស់ សូម្បីតែលោក អភិបាលស្រុករង ដែលបានអញ្ជើញចូលរួមដំណើរជាមួយយើងក្នុងពេលនោះ ក៏បានស្ញើចសរសើរដល់ក្រុម យើងផងដែរ ថាពិតជាមានឧត្តមគតិមែន ។ ពិតមែនហើយ! បើគិតពីផ្លូវរអិល ក្រហេងក្រហូង ដាច់ដុំៗ យើងពិតជាមិនគួរធ្វើដំណើរទៅទេ ប៉ុន្តែដោយមានការក្លាហាន ហ៊ានពុះពាររាល់ឧបសគ្គ ទើបធ្វើអោយយើងសម្រេចចិត្តភ្លាមៗថា ត្រូវតែធ្វើដំណើរទៅមុខរហូតដល់គោលដៅ ។ ប៉ុន្តែមុននឹងទៅដល់គោលដៅ រថយន្តរបស់យើងបានជាប់ផុង នៅចំណុចក្បែរអាងទឹកត្រពាំងថ្មនោះ អស់រយៈពេលជិតមួយម៉ោង ។ នៅ

ពេលដែលរថយន្តយើងជាប់ផុង ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរដោយថ្មើរជើងឆ្ពោះទៅអាងត្រពាំងថ្ម ដែលជាទីតាំងសម្លាប់ធំជាងគេក្នុងទូទាំងស្រុក ។ ចំងាយពីរថយន្តជាប់ផុង ទៅអាងត្រពាំងថ្ម មានចំងាយប្រហែល៣០០ម៉ែត្រ ។ ពេលដែលយើងបានទៅដល់អាងនោះ លោកអភិបាលស្រុករងបានមានប្រសាសន៍ប្រាប់យើងថា អាងនេះបានចាប់ផ្តើមជីកនៅឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៦ ដែលមានបណ្តោយ ១០ គីឡូម៉ែត្រ និងទទឹង ៧គីឡូម៉ែត្រ ហើយអាចផ្ទុកទឹកបានចំនួន ប្រាំពីរលានម៉ែត្រគីប ដើម្បីស្តុបទឹកសំរាប់ធ្វើស្រែប្រាំងក្នុងស្រុកពីរ គឺស្រុកព្រះនេត្រព្រះ និងស្រុកភ្នំស្រុក ។ លោកបានបន្តទៀតថា អាងទឹកនេះត្រូវបានពួកខ្មែរក្រហមប្រមូលប្រជាជនពីស្រុកថ្មពួក, ស្រុកសេរីសោភ័ណ និងស្រុកព្រះនេត្រព្រះ ជាពិសេសប្រជាជនដែលរស់នៅទូទាំងតំបន់ ៥ អោយមកជីក ។ ក្នុងចំណោមប្រជាជនដែលបានមកជីកអាងនេះ ភាគច្រើនគឺជាយុវជន យុវនារី ព្រមទាំងប្រជាជនដែលទើបតែជំលៀសមកពីភ្នំពេញផង ។

នៅពេលដែលយើងសួរថា តើមានប្រជាជនស្លាប់នៅទីនេះប៉ុន្មាននាក់នោះ លោកអភិបាលរង ស្រុកបានបញ្ជាក់ថា លោកមិនអាចកំណត់ចំនួនមនុស្សស្លាប់ក្នុងអាងនេះបានទេ ប៉ុន្តែលោកបានប៉ាន់ស្មាន ថាប្រហែលជាមានមនុស្សស្លាប់នៅទីនេះ **រាប់ពាន់នាក់** ហើយការស្លាប់របស់ពួកគេគឺមានទាំងការសម្លាប់ និងមានទាំងការអត់ឃ្លាន រហូតដល់ស្លាប់ផង ។ ចំណែកឯលោក **តាន់ មិញ** ជាប្រជាជនរស់នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ក៏បានបញ្ជាក់ផងដែរថា នៅក្នុងអាងទឹកនេះក៏មានរណ្តៅសំរាប់កប់សាកសពមួយចំនួនដែរ ប៉ុន្តែមានជាលក្ខណៈទ្រង់ទ្រាយតូច ហើយចំពោះអ្នកដែលបានស្លាប់នៅទីនោះ លោក **តាន់ មិញ** ក៏បានប្រាប់ដែរថា មានរាប់ពាន់នាក់ ដូចលោកអភិបាលស្រុករង បានបញ្ជាក់ដែរ ។ រីឯ លោក **គាត់ ឈឿម** រស់នៅភូមិ ឃុំ ស្រុកជាមួយលោក **តាន់ មិញ** ក៏បានបញ្ជាក់ដូចលោក **តាន់ មិញ** និងលោកអភិបាលស្រុករងដែរ ហើយម្យ៉ាងទៀត ក្រុមស្រាវជ្រាវយើងក៏មានសេចក្តីសោមនស្សរីករាយណាស់ដែរ នៅពេលដែលលោកអភិបាលស្រុករងឈ្មោះ **ឈុំ រួម** លោក **តាន់ មិញ** និងលោក**គាត់ ឈឿម** បានសុខចិត្តធ្វើជាសាក្សីក្នុងព្រឹត្តិការណ៍សម្លាប់មនុស្សក្នុងអាងទឹក ត្រពាំងថ្មនេះ ។

នៅវេលាម៉ោង ១២:៤៥នាទី ក្រុមស្រាវជ្រាវយើងបានបន្តដំណើរឆ្ពោះទៅកាន់វត្តកណ្តាល ដែលស្ថិតនៅភូមិស្រះឈូក ឃុំស្រះជីកទៀត ដើម្បីពិនិត្យមើលស្តូបមួយដែលផ្ទុកពេញទៅដោយអដ្ឋិធាតុ ដែលបានប្រមូលមកពីកន្លែងសម្លាប់នានាក្នុងទូទាំងស្រុកភ្នំស្រុក ។ វត្តកណ្តាលនេះ ស្ថិតនៅចំងាយប្រហែល ៥០០ម៉ែត្រ ពីទីរួមស្រុក ។

ការសន្និដ្ឋានពីរណ្តៅសាកសព គុកសន្តិសុខ និងកន្លែងតំកល់អដ្ឋិធាតុ នៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ព្រមទាំងសាក្សី ៖

នៅក្នុងទួទាំងស្រុកភ្នំស្រុក មានការកាប់សម្លាប់មនុស្សដែលមានទ្រង់ទ្រាយធំ មាន ៣កន្លែង, គុកសន្តិសុខ១កន្លែង និងកន្លែងតំកល់អដ្ឋិធាតុ១កន្លែង ។

**① ទីតាំងសម្លាប់នៅព្រៃគោកត្រាច**

-ស្ថិតនៅចំងាយ ១៥០០ម៉ែត្រ ពីសាលាស្រុក

-មានដើមពោធិមួយដើមសំរាប់សំគាល់

-មានការសម្លាប់យ៉ាងច្រើន, មានទាំងគ្រួសារផង

-ការប៉ាន់ស្មានមនុស្សដែលបានស្លាប់ ៖ មានចំនួនច្រើន (មិនអាចប៉ាន់ស្មានបាន)

-ប្រភេទជនរងគ្រោះលាយចំរុះ មានប្រជាជន, ទាហ៊ាន ដែលត្រូវឲ្យទៅទទួលសម្តេចឪ....

-គ្មានលក្ខណៈជារណ្តៅទេ

**② ទីតាំងគោកតាមុល**

-ស្ថិតនៅចំងាយ ២គីឡូម៉ែត្រ ពីសាលាស្រុក

-ក្រុមស្រាវជ្រាវយើងមិនបានចុះទៅទេ ហើយក៏គ្មានពត៌មានដែរ ព្រោះមានការលំបាកធ្វើដំណើរ ។

**③ ទីតាំងអាងទឹកត្រពាំងថ្ម**

-ស្ថិតនៅចំងាយ ៥គីឡូម៉ែត្រ និង ៩០០ម៉ែត្រ ពីសាលាស្រុក

-ចាប់ផ្តើមកសាងពីដើមឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ ១៩៧៦

-ប្រភេទជនរងគ្រោះ ច្រើនតែយុវជន យុវនារី អ្នកជំលៀសពីភ្នំពេញ

-ការប៉ាន់ស្មានចំនួនមនុស្សដែលស្លាប់ រាប់ពាន់នាក់

-ការស្លាប់របស់ពួកគេមាន ២ប្រភេទគឺត្រូវបានខ្មែរក្រហមសម្លាប់ និងស្លាប់ដោយអត់អាហាររួមជាមួយការធ្វើទណ្ឌកម្មផង ។

-មានរណ្តៅសាកសពមួយចំនួន(មិនអាចរាប់បានព្រោះនៅក្នុងទឹក) ដែលមានទ្រង់ទ្រាយតូច

**④ ទីតាំងគុកសន្តិសុខ**

-ស្ថិតនៅក្នុងបរិវេណសាលាស្រុកភ្នំស្រុក នាពេលបច្ចុប្បន្ន

-ប្រភេទជនរងគ្រោះ លាយចំរុះគ្នា

**⑤ សាក្សី**

នៅក្នុងស្រុកភ្នំស្រុកយើងមានសាក្សីសំខាន់ៗមួយចំនួនដូចជា ៖

-លោក **ឈុំ រួម** ជាអភិបាលស្រុក បានផ្តល់ពត៌មាន និងចុះផ្ទាល់ដល់ទីតាំង

-លោក **គាត់ ឈឿម** ជាប្រជាជនរស់នៅភូមិប៉ោយស្នួល ឃុំប៉ោយចារ ជាអ្នកឃើញជាក់ស្តែងក្នុងការសម្លាប់ និងប្រើទណ្ឌកម្មមកលើប្រជាជនដែលបានជីកអាងត្រពាំងថ្ម ។

-ឈ្មោះ **គាន់ មិញ** ជាប្រជាជនរស់នៅ ភូមិប៉ោយស្នួល ឃុំប៉ោយចារ ជាអ្នកបានឃើញ និងបានប្រាប់យើងថា មានរណ្តៅខ្លះៗ នៅក្នុងអាងទឹក ។

-លោកយាយ **ថន** ជាប្រជាជនរស់នៅ ភូមិប៉ោយស្នួល ឃុំប៉ោយចារ ជាអ្នកបានឃើញ នូវការសម្លាប់មនុស្សនៅព្រៃគោកគ្រាប ។